ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ១០៩ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតលេខាធិការដ្ឋានក្រុមការងារផ្នែកទេសចរណ៍**

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងារផ្នែកទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

**សម្រេច**

**ប្រការ១ .–**

ត្រូវបានបង្កើតលេខាធិការដ្ឋានក្រុមការងារផ្នែកទេសចរណ៍ ជាសេនាធិការជូនក្រុមការងារផ្នែកទេសចរណ៍ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | **ឯកឧត្តម** | **សេង ម៉េងហុង** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | លោកជំទាវ | វណ្ណ សេរីរ័ត្ន | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម | គង់ សូលីដា | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤. | ឯកឧត្តម | អាំង សុវណ្ណរ័ត្ន | អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ | អនុប្រធាន |
| ៥. | ឯកឧត្តម | ជុក ជំនោរ | អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍ និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

ផ្ទះលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

| | | | | |
|---|---|---|---|---|
| ៦. | លោកជំទាវ | ប៉ូច វលក្ខណ៍ | នាយិកាវិទ្យាស្ថានជាតិទេសចរណ៍ | សមាជិកា |
| ៧. | ឯកឧត្តម | ឆាយ ឃុនឡុង | នាយកសាលាវិជ្ជាជីវៈទេសចរណ៍ | សមាជិក |
| ៨. | ឯកឧត្តម | ឈុន មករា | អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានគ្រប់គ្រងទីភ្នាក់ងារដឹកជញ្ជូននិងមគ្គុទ្ទេសក៍ទេសចរណ៍ | សមាជិកអចិន្ត្រៃយ៍ |
| ៩. | ឯកឧត្តម | ផ្លុង ធឿន | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ១០. | ឯកឧត្តម | គឹម សេរីវុឌ្ឍ | អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្មស្នាក់នៅទេសចរណ៍ និងម្ហូបអាហារ | សមាជិក |
| ១១. | ឯកឧត្តម | ជួន ជ័យសត្យា | អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានជំរុញទេសចរណ៍ក្នុងស្រុក និងអប់រំការយល់ដឹងជាសាធារណៈ | សមាជិក |
| ១២. | ឯកឧត្តម | ហ៊ួត វិទ្ធី | អគ្គលេខាធិការរង និងជាប្រធាននាយកដ្ឋានសេវាគាំពារទីក្រុងស្អាត និងជំរុញការប្រឡងប្រណាំង | សមាជិក |
| ១៣. | លោកស្រី | ឡាយ កន្និកា | អគ្គនាយករងគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ | សមាជិកា |
| ១៤. | លោក | គង់ សុភារក្ស | ប្រធាននាយកដ្ឋានស្ថិតិទេសចរណ៍ | សមាជិក |
| ១៥. | លោក | ឃិន ណាត | ប្រធាននាយកដ្ឋានវិនិយោគទេសចរណ៍ | សមាជិក |
| ១៦. | លោក | មាន វ៉ាន់ដេត | ប្រធាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ | សមាជិក |
| ១៧. | លោក | ស៊ូ គឹមព្រឹទ្ធា | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ១៨. | លោក | សុខ វណ្ណា | ប្រធាននាយកដ្ឋានគ្រប់គ្រងសេវាកម្មកម្សាន្ត និងកីឡាទេសចរណ៍ | សមាជិក |
| ១៩. | លោក | ចាន់ ខេមរិទ្ធិ | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ផលិតផលទេសចរណ៍ | សមាជិក |
| ២០. | លោក | ហោ សុគន្ធ | ប្រធាននាយកដ្ឋានសន្តិសុខ និងសុវត្ថិភាពទេសចរ | សមាជិក |
| ២១. | លោក | សង់ វិសិដ្ឋ | សមាជិកខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី | សមាជិក |

**ប្រការ២ ._**

លេខាធិការដ្ឋានក្រុមការងារផ្នែកទេសចរណ៍មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំកិច្ចប្រជុំក្រុមការងារផ្នែកទេសចរណ៍
- ប្រមូល ពិភាក្សា និងសម្របសម្រួលសំណូមពររបស់ផ្នែកឯកជន ដើម្បីដាក់ស្នើក្នុងកិច្ចប្រជុំក្រុមការងារផ្នែកទេសចរណ៍
- សម្របសម្រួលកិច្ចការទូទៅពាក់ព័ន្ធទៅនឹងកិច្ចសហការរវាងរដ្ឋ-ឯកជនក្នុងវិស័យទេសចរណ៍
- រៀបចំ និងចងក្រងរបាយការណ៍បូកសរុបលទ្ធផលការងារជូន**ឯកឧត្តមរដ្ឋមន្ត្រី** និងជាប្រធានក្រុមការងារផ្នែកទេសចរណ៍
- អនុវត្តការកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនដោយ**ឯកឧត្តមរដ្ឋមន្ត្រី** និងជាប្រធានក្រុមការងារផ្នែកទេសចរណ៍។

**ប្រការ៣ ._**

សមាសភាពលេខាធិការដ្ឋានអាចធ្វើការកែសម្រួលតាមការចាំបាច់ តាមការសម្រេចរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** និងជាប្រធានក្រុមការងារផ្នែកទេសចរណ៍។

**ប្រការ៤ ._**

សេចក្តីសម្រេចនានាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវបានចាត់ជានិរាករណ៍។

**ប្រការ៥ ._**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ អគ្គនាយកអភិវឌ្ឍន៍ទេសចរណ៍និងសហប្រតិបត្តិការអន្តរជាតិ នាយិកាវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានីខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**សុខ សូកេន**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- មន្ទីរទេសចរណ៍រាជធានីខេត្ត
- សមាគមឧស្សាហកម្មទេសចរណ៍
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ